# វគ្គ

## ដើមបំពេញរាជ្យ

តាមពិតឈ្មោះរបស់ខ្ញុំគឺ ចន្ទា ប៉ុន្តែនៅរៀនសាកល ពួកម៉ាកចូលចិត្តហៅខ្ញុំថាអាដូច ព្រោះខ្ញុំជាកូនទោល ហើយមានមុខមាត់ រូបរាងកាត់ទៅរកពុក សូម្បីតែសក់ពែក និងដៃម្ខាងក្រង៉ែងៗ។

ពេលនិយាយស្ដីម្ដងៗ សំឡេងខ្ញុំ ក៏ម៉ែតែងចាប់ច្រឡំថាជាសំឡេងពុកដែរ។

ចំណែកអ្វីមួយដែលខ្ញុំមិនដូចពុកនោះគឺ ខ្ញុំមិនជឿទេ អារឿងមន្តអាគមអូមអាម ទោះបីជាធ្លាប់ឮនឹងត្រចៀកតាំងពីតូចរហូតចេញចោលភូមិមករៀននៅភ្នំពេញ។

ទីតៗ ទូរសព្ទខ្ញុំលាន់សារមក។

«ភូមិអ្អែងមានស្រីស្អាតច្រើនអត់អ្ហ៎!»

អាសាន់ (Sunday) ជាសម្លាញ់ស្នាក់នៅកុដិជាមួយគ្នាភ្នំពេញ។ មកដល់ស្រុកមិនទាន់អង្គុយក្ដៅគូទផង វាសរសេរមកសួរនាំរឿងស្រីៗ។ ទម្លាប់វាមិនដែលចោលទេអារឿងខូចកូនគេឱ្យតែបាន អស់អីក៏អស់ទៅ ប៊ិះត្រូវឪគេទៅរករឿងបីបួនដងហើយ គង់តែបានពួកម៉ាកនាំគ្នារកវិធីឱ្យគេច កុំអីអាសាន់មិនដឹងត្រូវគេចាប់ការប៉ុន្មានដងហើយទេ។

«គ្មានទេ! បើមាន អញក៏គ្មានជំពាក់អីត្រូវទៅប្រាប់អាវ៉ែងដែរ! ដេកទៅ! យាមបន្ទប់ឱ្យស្រួលផងវ៉ឺ!»

ខ្ញុំដាក់ទូរសព្ទចោល ជួនសំឡេងពុកខ្ញុំលាន់បង្គាប់មកពីក្រោមផ្ទះ៖

«ស្អែកក្រោកពីភ្លឺ ជូនអញទៅគាស់ដើមឈើនៅភូមិលិច!»

របរដកដើមឈើជារបរបន្ថែមរបស់គ្រួសារយើង។ នេះជាអ្វីដែលខ្ញុំដឹងពេលមកលេងផ្ទះលើកនេះ។ ផ្ទះយើងមានឡានចាស់ៗគ្រឹកពីរគ្រឿង តែវាមានប្រយោជន៍ណាស់ក្រៅពីការងារក្រឡឹង ហើយវាថែមទាំងអាចជួលដឹកជញ្ជូន ស្ទួចដកដើមឈើដែលគេឧស្សាហ៍ហៅ ព្រោះតែអ្នកស្រុកធូរធារសម្បូរសង់ផ្ទះ រំកិលដី។

ខ្ញុំមិនមាត់ទេដែលពុកប្រើ ព្រោះដឹងចិត្តថាគាត់នឹកចង់ឱ្យកូនប្រុសទៅជាមួយ តាមពិតគាត់មានកូនជាងហើយ។ ពួកគេនោះមាឌធំ កម្លាំងហំមិនមែនត្រដេវរិច លេងតែទូរសព្ទធុនខ្ញុំទេ។

«ស្អែកអាខ្នាទៅស្រុកវាដែរ! អញអផ្សុកណាស់ អញរកជិះទៅលេងផ្ទះអ្អែងដែរ ហើយមើលរកមាន់ស្រុកទុកដុតក្លែមផង! ចាំអញដឹកបៀរទៅ!»

«អ្អែងម៉ោធ្វើអី? អញរវល់ទៅដកឈើ!»

«ស្អី? ទៅដកឈើ?»

វាសួរមិនចេះចប់ទេ ខ្ញុំខ្ជិលឆាតតបវិញណាស់ ហើយប្រះដេកគងថ្ងាសគិត។ ពុកខ្ញុំមានកូនតែមួយ គាត់ចំណាស់ណេះហើយ នៅតែស៊ូការងារមិនចេះចប់សោះ ចុះខ្ញុំវិញ ទៅរៀនដល់ឆ្នាំទីពីរហើយ ក្រៅពីចេះថែមរឿងផឹកមួយមុខទៀត ដូចគ្មានឃើញរីកចម្រើនអីជាងកាលនៅភូមិសោះ?

ខ្យល់បក់ត្រសៀកៗជាមិត្តសម្លាញ់របស់មនុស្សកម្ជិលដូចខ្ញុំ...

បើមិនដេកស្រមុកខុរបានភ្លាម ម៉េចហៅថាអាដូច?

ទើបនឹងបិទភ្នែកភ្លឹប ស្រមោលខ្មៅធំមួយលោតមកផ្លោត ហើយសន្ធប់ជាន់ពីលើកខ្ញុំ។ ដង្ហើមខ្ញុំញ័រផឹតៗព្រោះទ្រូងថប់ ដៃជើងគាំងអស់ ក្បាលងាកមិនកើត មាត់ស្រែកមិនចេញ បានត្រឹមម្ហូបៗ...

អស្ចារ្យណាស់ រោគគាំងបេះដូងកើតឡើងពីអង្កាល់ ឬមួយជិះមកក្តៅពេកស្លឈាមឡើងគាំងស្រែកមិនទាន់។ ជួយផង...ខ្ញុំមិនចង់ទៅទាំងក្មេងទេ ប្រពន្ធមិនទាន់បានការផង អុះច្រឡំ គុណពុកម្តាយតែមួយកំប៉ុងអង្ករ ក៏មិនដែលបានសងជាកូនទោលផង យកខ្ញុំទៅទាំងអ៊ីចឹង បានពីណាមើលថែពួកគាត់?

ខ្ញុំរើអ៊ុះអ៊ុះតែឯង ប្រឹងបែកញើសង្វូង នៅតែដុំខ្មៅនោះមិនរបូត រហូតដល់សំឡេងធម៌លាន់ខ្ទរមកពីលើផ្ទះលាន់មកគ្រប់ទិសទាំងលិចកើតជើងត្បូង ទើបបានដុំខ្មៅហាក់បង្អង់ដៃខ្សោយកម្លាំងដែលសង្កត់កខ្ញុំរហូតចុងក្រោយរបូតខ្សាករលាយខ្សុលទៅក្នុងខ្យល់។

«អាថាៗ?»

អ្នកណាម្នាក់ជួយខ្ញុំដោយអង្រួនស្មាខាងឆ្វេងធ្វើឱ្យខ្ញុំស្រែកវ៉ាសភ្ញាក់ដូចគេជះទឹកដាក់។ សញ្ញាហត់គយូសបែកញើសជោកនេះ ធ្វើឱ្យគ្រប់គ្នាដែលឃើញ ដឹងហើយថាមានរឿងអីកើតឡើង។

ពូខ្ញុំឈ្មោះ អុក ដែលតែងតែមកបបួលផឹករាល់ពេលខ្ញុំមកលេងភូមិពេលនេះ គាត់បើកភ្នែកគ្រលួងសម្លឹងខ្ញុំ ដែលក្រោកមមីងមមាំង។

«ខ្មោចសង្កត់អ្អែង?»

ពូអុកសួរខ្សឹបៗ។ ខ្ញុំលើកដៃមកគ្រវាសជូតញើសដែលហូរផ្សាភ្នែក។

កន្ទុយភ្នែកខ្ញុំឃើញពូអ៊ុកដៀងសម្លឹងដើមឈើដែលនៅពីលើក្បាលដំណេកខ្ញុំមិញនេះ តែគាត់មិនបាននិយាយអ្វីបន្ថែមទៀយ។

«ហើយដេកអីថ្មើរហ្នឹងកូន? ថ្ងៃជាន់ហើយដឹង!»

ម៉ែសួរមកពីឆ្ងាយ ដៃគាត់មានកាន់រំដេងមួយគុម្ពមកជាមួយ គឺគាត់ទើបតែមកពីចម្ការខាងជើងផ្ទះ។ មិនឆ្លើយព្រោះឃើញពុកអើតពីលើមកមើល។

ពុកខ្ញុំពាក់អាវសដៃវែង មានពានាក្រមាលើស្មាឆ្វេងផង ជាទម្លាប់គាត់រាល់ពេលអុជធូប។

ឬមួយសំឡេងធម៌អម្បាញ់មិញមិនមែនជាការយល់សប្តិទេ?

«ពុកសូត្រធម៌ហ្មែនហ្នឹងពុក?»

ខ្ញុំស្រែកសួរគាត់។ ពុកហាក់ឡិងឡង់ មិនដឹងមិនយល់ពីសំណួររបស់ខ្ញុំ។

«មិញខ្ញុំស្មានតែពុកសូត្រក្នុងយល់សប្តិ?»

ខ្ញុំបង្ហើយ ធ្វើឱ្យគាត់ឈានតុបៗចុះមកទាំងធូបប៉ុន្មានសរសៃនៅជាប់ក្នុងដៃ។

«ថ្ងៃសីលណាកូន!»

ម្តាយខ្ញុំនិយាយប្រាប់ជំនួសពុក មុនពេលគាត់ដើរហួសទៅក្រោយ។ ខ្ញុំតាមមើលពុកដែលអុជធូបចោលរានម្ចាស់ទឹកដី តម្កល់ក្រោមម្លប់ស្វាយ។

«អ្ហែងយល់សប្តិរឿងអីខ្លះ អាដូច?»

ពូអ៊ុកខ្សឹបដេញដោល ធ្វើឱ្យខ្ញុំបង្វែរទិសងាកមកសម្លឹងគាត់វិញ។

អ្វីដែលខ្ញុំមិនអាចនិយាយចេញមកបានក្នុងពេលនេះ គឺការគិតរបស់ខ្ញុំដែលមិនដាច់ស្រេចថាតើស្រមោលខ្មៅនោះជាខ្មោចដូចដែលធ្លាប់ឮចាស់ៗតំណាល ហើយក្រោយមកក៏រលត់បាត់ដោយសារតែធម៌ពីលើផ្ទះ?

«មានគេផ្ញើសារឱ្យអ្ហែង!»

ពូអ៊ុកនិយាយ ហើយហុចទូរសព្ទមកឱ្យខ្ញុំដែរ។

ជាសាររបស់អាសាន់ដែលផ្ញើមកឥតល្ហែ ទោះខ្ញុំមិនតប ក៏វានៅតែផ្ញើ។

ខ្ញុំខ្ជិលអានបន្តិច ចង់អានបន្តិច ព្រោះក្រឡេកឃើញមានពាក្យថា «ពុកអ្ហែង»។ ខ្ញុំលូកដៃទទួលមកពិនិត្យឱ្យកៀក ព្រោះឃើញវាសរសេរវែង។

«ពុកអ្ហែងមានប្រាប់អត់? រឿងកាប់រំលំឈើ គេមិនមែនចេះតែធ្វើទេវ៉ី! នៅស្រុកអញ គេត្រណមច្រើនណាស់! អ្ហែងសួរចាស់ៗទៅ!»

ខ្ញុំមិនមាត់មិនក ចុចបិទ តែចិត្តពេញមួយយប់នោះនឹកឃើញតែរឿងមិនសូវល្អ មិនសូវស្រឡះចិត្ត។

ព្រឹកព្រលឹមឡើងគេក្រោកចោលខ្ញុំអស់ ខ្ញុំគេងមិនឆ្អែតមែន តែខំប្រឹងក្រោកទៅជាមួយគេដើម្បីឱ្យបានទាន់ឃើញពិធីគាស់ឈើ។

ម្ដាយខ្ញុំដួសបាយឱ្យ មានត្រីប្រឡាក់ និងសាច់អាំងខ្លះ។ ហូបបណ្ដើរ ខ្ញុំកេះសួរគាត់បណ្ដើរ៖

«ម៉ែ! ពុករកអារបរគាស់ឈើនេះយូរហើយ?»

ម៉ែឆ្លើយផង ធ្វើការចរច្រប់ក្នុងផ្ទះបាយតាមទម្លាប់គាត់៖

«របរអីកូន! យើងមានឡានស្ទូច គេចេះតែរក ពុកឯងក៏ចេះតែជួយៗទៅ! គាត់យកតែថ្លៃប្រេងទេ!»

ខ្ញុំឡើងទៅឈរក្បែរគាត់ ហើយសួរកាន់តែខ្សឹបខ្សៀយជាងមុន៖

«ដកឈើហ្នឹង គេមានត្រណមអីខ្លះដែរអត់?»

«គេធ្វើបរព្រៃសិន បានគេដក! ភាគច្រើនខាងម្ចាស់ផ្ទះគេធ្វើ!»

ខ្ញុំពមបាយបង្ហើយមួយម៉ាត់ចុងក្រោយ។ ពេលរមៀលចានចូលកន្ទន់ទឹករួចរាល់ ខ្ញុំកេះម៉ែសួរទៀត៖

«បរព្រៃហ្នឹង ស្អីគេទៅ?»

ម៉ែធ្វើទឹកមុខដូចហួសចិត្តដែលកូនចេញទៅភ្នំពេញរៀនមិនបានប៉ុន្មាន ត្រឡប់មកផ្ទះវិញធ្វើចរិតដូចជាអ្នកទីក្រុងសុទ្ធ។

«គេសែនព្រេនអីហ្នែន?» ខ្ញុំសួរបន្ថែម។

«គេធ្វើពិធីណាកូន! មិនត្រឹមសែនព្រេនទេ គេមានអាគមអួមអាមគេ!»

ខ្ញុំនៅស្ងៀម តែចិត្តភ្លឺស្វាងថៃសដែលពីមុនមកតែងតែមិនយកចិត្តទុកដាក់សោះពីរឿងអស់ទាំងនេះ។ ចំណែកម្ដាយខ្ញុំវិញធ្វើដូចធម្មតា។

«ទៅរកទឹកយកតាមខ្លួនខ្លះទៅកូន ប្រហែលថ្ងៃត្រង់អី បានហើយរួចរាល់ត្រឡប់មកផ្ទះវិញ!»

ខ្ញុំមិនមាត់សួរនាំអីទៀត ប៉ុន្តែធ្វើតាមពាក្យគាត់ប្រាប់។

ភូមិលិចក៏នៅមិនឆ្ងាយប៉ុន្មានគីឡូពីផ្ទះខ្ញុំប៉ុន្មាន ធ្វើដំណើរតាមរថយន្តស្ទួចប្រមាណជា ១៥ នាទីក៏ដល់ភូមិ តែចូលទៅកន្លែងដកឈើ ហាក់លំបាកត្រូវការពេលប្រមាណជាង ៣០ នាទីទៀត ព្រោះផ្ទះនោះនៅចុងភូមិក្បែរព្រៃ និងវាលដែលមានផ្លូវទៅទីនោះតូចចង្អៀត។

ក្នុងឡាន មានតែខ្ញុំ និងពុក ហើយនិងបងឌីនជាកម្មករជំនិតដែលពុកយកមកចិញ្ចឹមតាំងពីគាត់អាយុ ១១ ឆ្នាំ។

«គេដកឈើសង់ផ្ទះថ្មី?»

ខ្ញុំងាកសួរពួកគាត់។ បងឌីនមិនមាត់ គាត់ចង្អុលទៅដើមធំមួយនៅខាងមុខឡាន។

«ដើមមួយនេះ?»

ខ្ញុំសម្លឹងតាមចង្អុលដៃគាត់ប្រទះដើមបំពេញរាជ្យមួយធំ គឺធំយកមែនទែន។ គល់វាប្រហែលពីរឱបខ្ញុំឯណោះ? អ៊ីចឹងសោះបានគេចាំបាច់រកពុកឱ្យស្ទួចឱ្យ?

«មិនដឹងទេ! ចុះសិនទៅ ជួបតាឃឿនសិន!»

ពុកខ្ញុំឆ្លើយខ្លីៗ ហើយរុញបើកទ្វារលោតចុះ។ ខ្ញុំតាមមើលគាត់ ឃើញតាម្នាក់ស្លៀកខោអាចារ្យអាវសចេញមកទទួល ហើយរាក់ទាក់គ្នា។ ទំនងជាតាឃឿនដែលពុកទើបនឹងហៅឈ្មោះហ្នឹងហើយ។

នៅក្រោមផ្ទះ ពិតជាមានចាស់ៗបួនប្រាំនាក់នៅរង់ចាំ មានចេក ធូប និងទៀនផ្កា ហើយមានភ្លេងខ្មែរពីរបីឧបករណ៍ទៀត។

ចិត្តខ្ញុំនឹកឆ្ងល់ម្នាក់ឯង ហើយកាន់តែចង់ដឹងគ្រប់យ៉ាង។

ខ្ញុំអ្នកស្រែមែន តែរឿងនេះថ្មីសុទ្ធសម្រាប់ខ្ញុំ ចិត្តមួយថាងាកមករកសួរបងឌីន ឃើញគាត់រវល់តែអើតមើលឆ្វេងស្តាំទាំងរអ៊ូចុះឡើងម្នាក់ឯង៖

«ដើមហ្នឹងហើយ មានដើមណាទៀត?»

ខ្ញុំតបវិញដែរ៖

«ផ្លែចង់បាក់មែក! បើបេះលក់ ក៏បានមិនស្ទើរដែរ! ម៉េចចាំស្ទួចចោល?»

បងឌីនងាកមកខ្ញុំ ហើយនិយាយខ្សឹបខ្សៀវ៖

«សង្ស័យតែដើមហ្នឹងមិនស្រួល!»

ខ្ញុំចងចិញ្ចើម។

ក្រឡេកឆ្វាច់ទៅ នៅគល់ដើមបំពេញរាជ្យពិតជាមានសំណល់ផ្សែងធូបដែលឆេះជិតអស់មែន។ ខ្ញុំត្របាញ់ភ្នែកផ្តោតទីនោះ គាប់ជួនបងឌីនប្រាប់មកបន្ថែម៖

«មើលតែភ្លេងទៅ គេធ្វើបរព្រៃធំដុំអ៊ីចឹង មិនមែនធម្មតាទេ!»

«បរព្រៃជាស្អីទៅ? ដើម្បីស្អី?»

ខ្ញុំភ្លាត់មាត់សួរ បងឌីននិយាយពន្យល់មួយៗ៖

«បរព្រៃជារបៀនមួយ! ចាស់ៗជឿថា គេត្រូវតែសូត្រអញ្ជើញពួកអារុក្ខអារក្សអ្នកដែលទំនៅលើដើមឈើឱ្យចាកចេញទៅព្រៃសិន បានយើងចាប់ដំណើរការគាស់ឈើរំលើងបាន!»

ខ្ញុំនៅទ្រឹង ហើយងាកសន្សឹមៗសម្លឹងទៅចាស់ដែលកំពុងជជែកគ្នាឆ្ការដៃជើង។

សំឡេងបងឌីននៅតែមិនព្រមបញ្ចប់ គាត់និយាយបន្ថែម៖

«កន្លែងខ្លះគេសូត្រតិចតួច លាងអាហារមួយថាសពីរថាស ក៏ចាប់ផ្តើមគាស់គល់បានហើយ! មិនដឹងម៉េចក៏នៅភូមិនេះ គេធ្វើធំដុំម៉េះ? អាថា អ្អែងមិនដែលបានមករំលើងឈើម្តងទេ?»

ខ្ញុំងាកមកវិញភ្លាម តែខ្ញុំមិនឆ្លើយនឹងគាត់ ព្រោះខ្ញុំមានសំណួរផ្សេង៖

«មិញបងឯងថាដើមហ្នឹងមានបញ្ហា?»

សំឡេងពុកខ្ញុំលាន់កាត់មកពីក្រៅឡាន។

«អាឌីន អ្អែងថយមកខាងណេះសិន! ទុកកន្លែងគេធ្វើពិធី!»

បងឌីនដៃរាវរកចង្កូតសាជាថ្មី តែមាត់គាត់ឆ្លើយនឹងខ្ញុំ៖

«បងចេះតែថាតាមស្មានទេ! អ្អែងមើលមើល៍អាថា! ចាស់ៗមកច្រើនម៉េះ បើគ្រាន់តែគាស់ឈើរំលំធម្មតា គេបង្រ្គប់កិច្ចតិចតួច ចាំបាច់អីមានពិណពាទ្យមកតាម?»

ខ្ញុំបើកភ្នែកគ្រលួងផ្តោតលើពួកអ្នកស្រុកដែលដើរមកបន្ថែម។ ពួកគេលើកគ្រែឫស្សីតូចមួយតម្រង់យកមកដាក់ក្រោមគល់ដើមបំពេញរាជ្យ ចំណែកបងឌីនចាប់ផ្តើមរីយ៉ៃរឡានថយចៀសចេញ។

«ចុះមកកូន!»

ខ្ញុំរុញទ្វារ ហើយហក់ចុះតាមពាក្យពុកហៅ។

គាត់ងាកទៅនិយាយជាមួយចាស់ៗទៀត ហាក់មិនរវល់វត្តមានខ្ញុំនៅពីក្រោយខ្នង។ តាម្នាក់ដែលខ្ញុំសង្ស័យថាឈ្មោះឈឿន តាមពិតគឺឈ្មោះហ្នឹងមែន ព្រោះឮពុកខ្ញុំនិយាយនឹងគាត់បន្តះ

«ឈឿនឯងរកអ្នកពិណពាទ្យមកធំដុំម៉េះ?»

តាឈឿនឈោងដៃមកឱបចង្កេះកៀងពុកខ្ញុំទៅម្ខាង ហើយគាត់ខ្សឹបខ្សៀវះ

«ធីឯងមើល! ដើមបំពេញរាជ្យនៅហ្នឹងយូរ ហើយមានអ្នកណាដឹងថាវាមានរឿង? ផ្លែហូបមិនចេះអស់តែមនុស្សចេះតែឈឺ! កាលពីបងខ្ញុំនៅ គាត់ធ្លាប់ប្រាប់ដែរថាធ្លាប់យល់សប្តិឃើញភូមិនៅលើចុងឈើហ្នឹង តែពួកខ្ញុំចេះតែវាហី! ក្រោយមកគាត់ស្លាប់បាត់! ម្សិលម៉្ងៃ មុនពេលខលទៅរកធីឯងហ្នឹងមានអ៊ំមួយគាត់មកពីកំពង់ស្ពឺ គាត់មកលេងចៅគាត់ ហើយដើរមកកាត់នេះចុះទៅស្ទឹង! គាត់ប្រាប់ថាដើមនេះទុកលែងបានហើយ! មែកវាមើលទៅមិនស្រួល!»

ពុកខ្ញុំសន្សឹមៗងាកទៅទៅសំឡេងរុក្ខាដ៏ធំមាំ ហើយខ្ពស់សង្ហានោះ។

ខ្ញុំក៏ធ្វើតាមពីក្រោយគាត់ដែរ។

ពុកមិននិយាយអ្វីតបចំពោះម្ចាស់ផ្ទះ តែខ្ញុំដឹងថា គាត់កំពុងគិតមិនខុសពីខ្ញុំទេ។ ដើមនេះធំត្រៃឈៃកាប់ចោលស្តាយពេកហើយ!

មិនដឹងថា ម្ចាស់ផ្ទះត្រូវប្រឈមនឹងអ្វីខ្លះនោះទេបានជាត្រូវបង្ខំចិត្តបោះបង់រុក្ខាដ៏មានអត្ថប្រយោជន៍ទាំងជាម្លប់ ទាំងជាកម្លាំងការពារខ្យល់ ប្រភពផ្តល់ឱជារស និងជាញាតិលម្អមុខផ្ទះច្រើនឆ្នាំមកហើយ។

«ធីឯងមើល! មែកវាបែកចេញជាពីរ រាងដូចជាចម្លាមដូចគេគ្រី! ខ្ញុំគិតថា វាស្អាតហើយចម្លែក! ត្រឈឹងត្រឈៃល្អ! ពេលអ៊ំនោះឃើញ គាត់ថាដើមឈើបែកមែកជាចម្លាមគេមិនឱ្យទុកទេ! គាត់ថាស្រុកគាត់គេទុកចោល រើផ្ទះចេញឆ្ងាយ ឬមួយគេដកឈើចោល! តែខ្ញុំនឹកមិនអស់ចិត្តនាំកូនប្រពន្ធទៅសួរចាស់ៗដល់ស្រុកលើ! មានអ្នកខ្លះគេថាអ៊ីចឹងដែរ! គេថាគេឱ្យដកចោល!»

«បើបងឈឿនឯងរស់នៅសុខសប្បាយទេ! ចាំបាច់អីពិបាកចិត្តដកតាមគេប្រាប់!»

ពុកខ្ញុំ ធម្មតាគាត់ជាមនុស្សមានជំនឿច្រើនលើរឿងអាគមអូមអាមអីអស់នេះ តែលើកនេះគាត់និយាយត្រូវចិត្តខ្ញុំមែន។

ខ្ញុំនៅទ្រាំរង់ចាំការឆ្លើយតបយ៉ាងអន្ទះសា ស្រាប់តែសំឡេងស្រ្តីចំណាស់ម្នាក់ទៀតស៊កមកពីក្រោយខ្នងតាឈឿន៖

«សុខសប្បាយអី ចឹកអើយ! មួយរយៈនេះយល់សប្តិឃើញតែផ្តាស! កូនខ្ញុំរៀននៅភ្នំពេញវាខលមកនិយាយថា យល់សប្តិឃើញមានគេសំងំលើដើមឈើមុខផ្ទះ គប់ថ្មភ្នំធំៗមកលើខ្ញុំ និងឪវា រត់ជ្រកមិនចង់ទាន់! រំលងបានប៉ុន្មានថ្ងៃ មានអ៊ំមកពីកំពង់ស្ពឺ គាត់ដើរកាត់ហើយនិយាយប្រាប់ទាំងព្រួយបារម្ភ! ចឹកឯងមើល មានម្តងកូនស្រីខ្ញុំសុខភាពល្អមិនដែលអី អាទិត្យមុនគ្រាន់តែគ្នានិយាយលេងៗថាឱ្យតែមានលុយគាស់ដើមបំពេញរាជ្យចេញសង់ផ្ទះថ្មឱ្យម៉ែនៅ នៅសុខៗស្អែកឡើងធ្លាក់ខ្លួនឈឺក្អួតឈាមក្រហមច្រាលទៅពេទ្យមិនចង់ទាន់! ខ្ញុំរកគ្រូខ្មែរមើលគេថា ឱ្យមកអុជធូបសុំខមាទោសដើមឈើ! ខ្ញុំក៏ធ្វើតាម តែកូនខ្ញុំនៅតែដេកយល់សប្តិអាក្រក់មិនបាត់សោះ! មើលទៅដូចជាមិនកើតហ្នឹងហើយបានជាខ្ញុំសម្រេចចិត្តនិយាយឪវាឱ្យហៅចឹកមក!»

ពុកខ្ញុំដូចជាមានអារម្មណ៍មិនសូវល្អ ចេះតែងាកទៅសម្លឹងដើមឈើនោះ។ កុំថាឡើយតែគាត់ សូម្បីតែខ្ញុំឮសម្តីប្តីប្រពន្ធម្ចាស់ផ្ទះបែបនេះហើយ ក៏លែងចង់គាស់ទៀតដែរ។

បងឌីនមិនដឹងមកដល់តាំងពីពេលណា គាត់មកលាន់មាត់ឡើងក្រោយខ្នងខ្ញុំ៖

«ពូឯងរកគ្រូខាងណាមកធ្វើបរព្រៃហ្នឹង? ខ្ញុំធ្លាប់តែឃើញគេសែនបង្គ្រប់ធម្មតាៗ។»

គ្មានអ្នកណាមាត់ ព្រោះតាឈឿនខ្លួនគាត់ក៏ចោលការសន្ទនា ហើយផ្តោតសម្លឹងទៅពួកអ្នកស្រុកដែលកំពុងរៀបចំបាយសី និងដាក់គ្រឿងដង្វាយទៅលើគ្រែឫស្សីក្រោមម្លប់បំពេញរាជ្យនោះ។

ពួកអ្នកភ្លេងក៏ប្រមូលឧបករណ៍ដើរទៅជាជួរតាមពីក្រោយ។

នាំមុខពួកគេគឺបុរសវ័យកណ្តាលម្នាក់មានសាច់ទ្រលុក។ គាត់នោះគ្មានពុកមាត់ពុកចង្កាទេ តែគាត់គូរមុខមាត់ស្លៀកពាក់ក្រហមលាយលឿងចងក្បិនទក់ទីខ្ញីខ្ញុក។ ចង្កេះគាត់ចងក្រមាពីរបីជាន់ជើងមានពាក់កងដែក។

«តោះបងឈឿនអើយ! ហៅជាងគាស់មកចាប់ផ្តើមពិធីទៅ! មិនមែនខ្ជីទេណា៎! ស្រួតឱ្យហើយ មុនថ្ងៃត្រង់!»

តាម្នាក់ទៀតដែកាន់ទ្រអ៊ូមាត់ស្រែកហៅតាឈឿន និងភរិយា។

បងឌីនងាកមកមើលមុខខ្ញុំ ហើយមើលមុខពុក។ មើលហើយកាលណា គាត់និយាយរឹងថាឱ្យម្ចាស់ផ្ទះ៖

«ពួគួរតែធ្វើពិធី ហើយចាំឱ្យពួកខ្ញុំមកដល់បានធ្វើការហ្នុង!»

តាឈឿនប្រកែកញ៉ាញ៖

«ម៉េចបាន? គេរកមុខអ្នកគាស់ហ្នឹងហើយសំខាន់ជាងគេសម្រាប់ធ្វើពិធី!»

បងឌីនចំហមាត់ ស្របពេលសំឡេងប្រកូកលាន់ឡើង។

«ឯណាអ្នកជាងគាស់កាយ? ឆាប់មកណេះៗ! រហ័សបន្តិច!»

ពុកខ្ញុំងាកទៅរកមើលប្រភពដែលស្រែកហៅ។ គឺបុរសចំណាស់ដែលស្លៀកក្បិនពាក់អាវក្រហមលាយលឿងម្នាក់ហ្នឹងហើយដែលកំពុងនិយាយប្រកូកផង រំពៃមើលមកពួកយើងផង។

ពុកបង្គាប់ទៅកាន់បងឌីន៖

«ទៅនិយាយជាមួយគាត់មើល៍!»

បងឌីនទីទើរ អ្នកស្លៀកក្រហមក៏ដើរមករកគាត់។

ពួកយើងសុទ្ធតែនៅស្ងៀមចាំស្ដាប់បុរសនោះ។

«ប្អូនឯងដោះអាវទៅ!»

គាត់ថាផង ដោះក្រមាពីថ្មីថែសពណ៌ក្រហមចេញពីចង្កេះមកផង។ ខ្ញុំ និងបងឌីនសុទ្ធតែង៉េមង៉ាមម៉្លោះហើយពុកខ្ញុំលូកដៃមកទាញអាវគាត់ដោះ។

បងឌីនកន្លងមកគោរពពុកណាស់។

គាត់រស់ជាមួយយើងជាង ១០ ឆ្នាំហើយ ទោះពុកមិនដែលហៅគាត់ថាកូនធម៌ ប៉ុន្តែក្នុងចិត្តគ្រប់គ្នាបងឌីនជាកូនច្បងរបស់ផ្ទះខ្ញុំ កម្មករផ្សេងៗទៀតគោរពគាត់ដូចគោរពពុកដែរ។

ម៉ែខ្ញុំមើលថៃគាត់ ពេលគាត់ឈឺថ្កាត់ ដូចកូនប្រុសចេញពីផ្ទៃពិតៗ។ ពេលនេះគាត់ដោះអាវ ហើយនៅផ្ទឹងឱ្យអ្នកស្លៀកក្បិននោះលូកមកទាញក្រមាពាក់ពានាឱ្យគាត់។

គេបណ្ដើរគាត់ទៅក្រោមម្លប់ឈើ ហើយពុកដើរចរច្រប់ទៅតាម។

ខ្ញុំទាញទូរសព្ទ ហើយត្រៀមថត...

ទីសក្ការបូជាដែលនៅចំពោះមុខខ្ញុំនេះ គឺគេធ្វើនៅលើគ្រែឫស្សីមួយនោះតែម្ដង ចំណែកបងឌីន គេក្រាលកន្ទេលឱ្យគាត់អង្គុយ ទល់មុខគ្នានឹងអ្នកស្លៀកក្បិន។ នៅម្ខាងទៀត ពួកអ្នកភ្លេងអង្គុយបត់ជើងផ្ទាល់លើកន្ទេលមួយផ្សេងជាមួយនឹងពានទ្រផ្លែឈើធំនៅចំពីមុខ។

«ម្ចាស់ផ្ទះចូលមកអាយ!»

តាចាស់ម្នាក់ដែលមានរូបរាងស្គមស្គាំងដូចមានជំងឺ តែមានពាក់ខ្សែកភ្លុកធំៗ ហៅតាឈឿន និងប្រពន្ធដោយសម្លឹងមកផង។

អ្នកស្រុកពេលនេះ បានចំនួនសរុបជាងម្ភៃនាក់ហើយ។ ពួកគេនាំគ្នាមកអង្គុយលើកន្ទេលបួនប្រាំដែលត្រូវបានក្រាលចំពីមុខគ្រែពិធី។ ខ្ញុំក៏ដោះស្បែកជើងទៅចូលរួមអង្គុយសង្រួមឫកពាជាមួយពួកគេដែរ។ អ្នកភូមិជាយាយចាស់ៗពីរនាក់ទៀតលើកគ្រឿងសែនជាបង្អែម និងចម្អាបមួយថាសចេញមក ពួកគេព័ទ្ធថាសនោះដោយស្លឹកចេកមានរាងជាពែ គ្រាន់តែមិនមានកាត់ជារូបរាងមនុស្សទេ។

«តាឈឿនឆាប់មកអុជធូបសែន!»

លោកតាដែលមានពាក់ខ្សែកភ្លុកធំៗ ហៅបន្ថែមស្របពេលតាឈឿនដើរទៅដល់។ គាត់ក៏ហុចធូបដុតហើយស្រាប់ជាច្រើនសរសៃឱ្យទៅគាត់។ តាម្ចាស់ផ្ទះទទួលធូបផង ដៃមួយទៀតទទួលសំណុំម្ហូបបាយក្នុងថាសដើមចេកដែលយាយៗហុចមកឱ្យនោះផង។

«យកទៅដាក់ក្រោមគល់ ហើយមកអង្គុយក្បែរអ្នកគាស់កាយ!»

តាឈឿនធ្វើតាមបង្គាប់អ្នកពាក់ភ្លុកមិនហ៊ានតបតអ្វី។ លុះបានដាក់គ្រឿងសំណែនហើយ ក៏ថយមកអង្គុយពីមុខគ្រែក្បែរៗបងឌីន ប្រឈមមុខទៅនឹងអ្នកស្លៀកក្បិន។ ខ្ញុំដកភ្នែកពីតាចាស់ពាក់ភ្លុកដែលជាអ្នករៀបចំពិធីងាកមកសម្លឹងអ្នកស្លៀកក្បិនក្រហមស្លឿងវិញ។

បុរសនេះលើកដៃប្រណម ហើយបិទភ្នែកទាំងសង មាត់ទន្ទេញធម៌ញាប់ស្អេក។ លោកតាដែលមានភ្លុកបានបោះផ្កាច្រើនពណ៌ដែលគេបេះរាយទុកជាស្រេចក្នុងចានមកពាសពេញលើអ្នកស្លៀកក្បិន ហើយថែមទាំងបាញ់ទឹកអប់ក្រអូលឆ្អួលច្រាល។

ភ្លាមនោះគាត់ស្រែកតែម្នាក់ឯងឡើងថា៖

«ដល់ពេលហើយវ៉ី! ឯណាទៅព្រៃ អញចូលបង្ហាញ!»

បានឮដូច្នេះកាលណា ពួកភ្លេងចាប់ផ្ដើមកម្រើក ដោយស្គរដីក៏ទូងនាំមុខ ហើយអ្នកភ្លេងដែលកាន់ឧបករណ៍ផ្សេងទៀតចាប់ចេញមករួមដំណើរជាចង្វាក់។ អ្នកស្លៀកក្បិនស្រាប់តែលែងប្រណម ហើយមកចាក់ក្បាច់រាំរំពើនពត់ដូចអ្នករបាំយ៉ាងប៉ិនប្រសប់នៅចំពីមុខបងឌីន។

បងឌីនវិញត្រូវចាស់ៗចូលមកកេះឱ្យគាត់ឱ្យអង្គុយសំពះផ្គោមៗមិនឈប់ តែខ្ញុំយល់អារម្មណ៍គាត់។ ប៉ុន្មានឆ្នាំថ្មីៗនេះ ពិធីសែនព្រៃនកាន់តែធ្វើស្មុគស្មាញ និងច្រើនបែបបទឡើងក្នុងចំណោមអ្នករកស៊ីបុកគ្រឹះ ធ្វើការដ្ឋានសំណង់ និងគាស់ឈើរានដី។

អ្នកភូមិភាគច្រើនបានសន្មតគ្នា រាល់ដើមឈើសុទ្ធតែមានអ្នកថែរក្សារស់នៅ ហើយរាល់ការកាប់ទន្ទ្រានដោយគ្មានហេតុផល ឬធ្វើតាមប្រពៃណី ច្រើនតែនាំមកនូវឧបទ្រព។ រឿងលើកនេះខុសគ្នាបន្តិចត្រង់ថា ម្ចាស់ផ្ទះសង្ស័យពីភាពឧបទ្រពនៃឈើនេះហើយ បានជាពេលនេះគេធ្វើពិធីមុនគាស់រំលើង។ ប៉ុន្តែ អ្នកណាទៅដែលគេកំពុងសុំ? ធ្វើម៉េចដឹងថា ការសុំបានជោគជ័យឬអត់? ខ្ញុំគិតហើយបងឌីនក៏គិតស្រដៀងគ្នាបានជាឃើញគាត់ងាកមកសម្លឹងខ្ញុំ និងពុកជារឿយៗ។

ពុកវិញ គាត់អង្គុយនៅក្បែរចាស់ជជែករអ៊ុះ មិនអាចស្ដាប់បានទេ។ បើនៅជិតវិញខ្ញុំ មានសំណួរច្រើនណាស់នឹងសួរគាត់។

ក្រឡេកទៅលើគ្រែវិញ តាស្លៀកក្បិនចាប់ផ្ដើមអុជធូបសូត្រមាត់ជីបអួចៗ។ យូរៗម្ដង គាត់ប្រោះទឹកដែលប្រើទងផ្កាជ្រលក់ពីក្នុងផ្ដិលមកប្រោះព្រំលើប្ដីប្រពន្ធម្ចាស់ផ្ទះ។

រំពេចនោះ ខ្ញុំក៏ឮសំឡេងបុរសស្លៀកក្បិនស្រែកសម្លុតឡើងញាប់ស្មោសមឱ្យភ្ញាក់ផ្អើលភ័យស្លន់បាន។

គាត់និយាយញាប់ណាស់ បិទភ្នែកទាំងសងខាង ដៃរាំចុះឡើងតាមកម្លាំងចង្វាក់ភ្លេង ធ្វើឱ្យខ្ញុំចំហមាត់ភ្លេចខ្លួនលែងចុចទូរសព្ទថត។

ចិត្តមួយប្រឹងផ្ទៀងស្ដាប់ទម្រាំនឹងបានឮពាក្យដូច្នេះថា «អញហៅនាងចេញ នាងចេញមកអាយ នាងប្រឹងនាងឆ្លៀតចរចាឱ្យអញ បានដឹងរឿងធាតុ បើនាងមិនឃ្មាត អញហៅមិនល្ហែ!»

គាត់ស្រែកដដែលៗ សឹងថាស្រួយស្រើបចាក់ត្រចៀកឱ្យផ្សាឈឺចាប់រំខាន។ គ្រប់គ្នានៅបង្អង់ស្ងៀមលែងមាត់អ្វី ហើយផ្ចង់សម្លឹងតែលើបុរសនោះម្នាក់ប៉ុណ្ណោះ ធ្វើឱ្យបរិយាកាសប្រែទៅជាស្ងប់ ឮតែសំឡេងគាត់គ្រលួចឡើងៗខ្ទរដល់ដើមឈើតូចធំ។

ស្រាប់តែមិនបានប៉ុន្មាន គាត់ក៏រលត់សំឡេងឈឹង ហើយទន់ខ្លួនឈ្ងោកមុខបម្រុងតែនឹងដួល។ បងឌីនថយក្រោយតិចៗ រហូតចាល់នឹងតាឈឿន ទើបគាត់លែងថយ។ ស្គរ និងភ្លេងនៅតែបន្តក្រោមបរិយាកាសទទ្ទឹងរង់ចាំរបស់គ្រប់គ្នា។ ពេលនេះទើបខ្ញុំនឹកឃើញលើកទូរសព្ទមកចុចផ្តិតយកទិដ្ឋភាពនៅចំពោះមុខ...

បុរសស្លៀកក្បិនស្រាប់តែបើកភ្នែកមកវិញធ្វើក្រឡោតៗ ហើយសម្លក់បងឌីន។ ខ្ញុំឯណោះក៏ភ័យសឹងដាច់ផ្ងារដៃទម្លាក់ទូរសព្ទចុះឃីតៗ។ សំឡេងអ្នកស្លៀកក្បិនប្រែទៅជាញែក ហើយនិយាយភាសាអ្វីមិនដឹងក្នុងសំនៀងតូចឆ្មារដូចកូនក្មេង។ គាត់និយាយម្នាក់ឯងចុះឡើងត្រឡប់ត្រឡិន និយាយតាំងពីខ្លួនឯងនៅនឹងនរហូតដល់ញ័រញាក់កន្ទ្រាក់ៗរង្គើអស់រាងកាយ។

ភ្លេងលេងកាន់តែញាប់តាមដែរ ហើយតាពាក់ភ្លុកបានលើកក្អមអង្ករមួយមានដោតធូបក្នុងនោះមករាំងចំពីមុខអ្នកស្លៀកក្បិន។

«កុំខ្លាច មើលមុខវាទៅ!»

គាត់ងាកប្រាប់បងឌីន ហើយទើបអង្គុយក្បែរនោះ ស្រែកតទល់នឹងអ្នកស្លៀកក្បិន។

«ផ្ទះឯងនៅក្នុងព្រៃ មកធ្វើអ្វីភូមិអ្នកស្រុក?»

ពុកខ្ញុំកេះបងឌីនឱ្យងើបមុខតទល់សម្លឹងអ្នកស្លៀកក្បិនតាមលោកតានោះបង្គាប់។ ខាងតាពាក់ភ្លុកគាត់ស្រែកចុះឡើងស្តាប់មិនយល់ ព្រោះញាប់ស្មេ ហើយភាគច្រើនជារបៀនចាស់។

ឯខាងអ្នកចូលរូបអស់ពីនិយាយញែក ក៏ស្រែកទួញយំជាភាសាអ្វីក៏មិនដឹង ស្តាប់មិនបាន យល់មិនកើត។ ប៉ុន្តែបានបន្តិចក្រោយមក អ្នកស្លៀកក្បិនក៏ឈប់ទួញត្អូញ បែរជាងក់ក្បាលឆ្លើយតបតក្អួរៗនិយាយតបកំបុតខ្លីៗ។ ដង្ហើមគាត់ដកហត់ទៅៗ ដង្ហក់ទៅៗ មិនយូរប៉ុន្មានគាត់ក៏ដួលសន្លប់ផ្ងោលនៅនឹងមុខអ្នករាល់គ្នា។ ពួកភ្លេងឈប់លេង ហើយចាស់ៗចាប់ផ្តើមក្រោកមកលើកអ្នកសន្លប់ឡើងហើយគ្រាចូលទៅខាងក្នុងផ្ទះ។ បងឌីន និងពុកខ្ញុំនៅអង្គុយមើលគេឯង ព្រោះមិនដឹងត្រូវធ្វើអ្វីចាប់ពីណាទៅណារហូតដល់តាឈឿនក្រោកមកប្រាប់៖

«តោះ ចាត់ការការងារយើង! គេព្រមឱ្យធ្វើហើយ!»

ខ្ញុំនៅបើកភ្នែកមូលក្រឡង់មើលពិធីនេះទាំងយល់ខ្លះមិនយល់ខ្លះ។

អ្វីដែលគាត់យល់ខ្លួនឯងបានគឺថា បុរសស្លៀកក្បិនបានប្រាវព្ធការចូលរួមជាមួយអារុក្ខអារក្សអ្នករក្សាដើមរុក្ខាត្រឈៃមួយនេះ ហើយក្រោយមក ការចរចារវាងអ្នកដែលមិនមានរូបពិតទាំងនោះបានកើតឡើងជាមួយតាពាក់ភ្លុក។

ឥឡូវនេះគ្រប់គ្នាជួយជញ្ជូនគ្រែចេញវិញ រីសំណែនទាំងអស់ត្រូវបានគេទុកចោលក្បែរគល់ដើមបំពេញរាជ្យ។ ខ្ញុំក៏ក្រោកឡើងថយឆ្ងាយពីកន្ទេលដែរ។ ដៃបងឌីនប៉ះក្រមាដែលពាក់ឆៀងលើខ្លួនគាត់ហាក់ទីទើរចង់ដឹងថា គាត់អាចដោះវាចេញបានហើយឬនៅ?

ពុកខ្ញុំចាប់ផ្ដើមទាញគាត់ឱ្យក្រោកឈរឡើង ព្រោះកន្ទេលដែលគាត់អង្គុយជាកន្ទេលសល់ចុងក្រោយ ក្រៅពីនោះ គេបានសាឡើងអស់ហើយ។

«ពួកខ្ញុំធ្វើបានហើយ?»

គាត់សួរតាឈឿន ធ្វើឱ្យតាម្ចាស់ផ្ទះងាកទៅសួរនាំតាពាក់ភ្លុកបន្ត៖

«ចាប់ផ្ដើមគាស់ឬម៉េច?»

តាពាក់ភ្លុកក៏បោះលម្អងផ្កាមួយក្ដាប់លើដៃរបស់គាត់ទៅលើក្បាលបងឌីន និងពុកខ្ញុំ មុនពេលនិយាយប្រាប់៖

«ធ្វើចុះ!»

ពិធីទាញគាស់រំលើងដើមបំពេញរាជ្យបានប្រព្រឹត្តទៅដោយរលូន។ នៅតាមផ្លូវវិលមកផ្ទះវិញ ខ្ញុំចាក់វីដេអូដែលថតបាននោះ មើលហើយមើលទៀតមុនពេលនិយាយម្នាក់ឯង៖

«ចូលរូបមែន ឬមួយគេចេះតែធ្វើៗ?»

ពុកខ្ញុំសួរមកកាន់ខ្ញុំវិញភ្លាម៖

«គេបោកប្រាស់ដើម្បីអី?»

ខ្ញុំមិនមានចម្លើយទេ ដូច្នេះក៏ប្ដូរការសន្ទនានេះទៅជាសំណួរវិញ៖

«រាល់ដង គេរំលំឈើចំណាយច្រើនអ៊ីចឹងដែរអត់ពុក?»

«ដើមនេះមានបញ្ហាខុសពីដើមផ្សេងៗ! ដើមឈើដែលធំចាស់ឆ្នាំ ហើយមានមែកបែកជាពីររាងដូចចម្លាមក្មេងបាញ់ គេហៅថាដើមបែកចម្លាម! តាមថា គេមិនដែលទុកក្បែរផ្ទះយូរទេ! តាឈឿនគាត់

មិនដឹង បានជារង់ចាំដល់មានរឿងរីករវ បានសម្រេចចិត្តកាប់ចោល! អ៊ីចឹង តាមក្បួនគេថា វាជ្រុល ដំណើរ ត្រូវតែធ្វើពិធីច្បាស់លាស់! បើឈើធម្មតាៗ គេដាក់តែចេកមួយស្និត រួចបាត់ហើយ»។